# កម្មវិធីអាហារូបករណ៍ផ្នែកប្រព័ន្ធផ្សព្វផ្សាយ




www.newsmekong.org 2011

**Inter Press Service (IPS) Asia-Pacific** និង **Probe Media Foundation Inc (PMFI)** សូម ធ្វើការអញ្ជើញ អ្នកសារព័ត៌មាន អ្នកថតរូប និង អ្នកបំរើការផ្នែកទូរទស្សន៍ ដើម្បីចូលរួមដាក់ពាក្យ យកអាហារូបករណ៍ក្នុងកម្មវិធីនិមិត្តរូបនៃដងទន្លេមេគង្គរបស់យើង (Imaging Our Mekong) សំរាប់ជុំទី៨ ក្នុងឆ្នាំ ២០១១-២០១២ នេះ។ កម្មវិធីអាហារូបករណ៍ ប្រចាំឆ្នាំនេះ គឺផ្តោតទៅលើ ទស្សនះវិស័យនៃតំបន់ទន្លេមេគង្គក្នុងខណៈពេល នៃសកលភាវូពាណិជ្ជកម្មដែលសំដៅជាសំខាន់ ទៅលើបញ្ហាទៅវិញទៅមកដែលជាលទ្ធផលនៃការអភិវឌ្ឍន៍តំបន់។

កម្មវិធី **Imaging Our Mekong** គឺបើកអោយប្រកួតប្រជែងសំរាប់តែប្រទេស កម្ពុជា ឡាវ ថៃ វៀតណាម និងចិន។ សំរាប់អាហារូបករណ៍ក្នុងជុំ ២០១១-២០១២ នេះ មាន ១៥កន្លែង ដែល៥កន្លែងសំរាប់អ្នកសរសេរអត្ថបទ ២កន្លែងសំរាប់អ្នកថតរូប និង ៨កន្លែងទៀតសំរាប់អ្នកយក-ព័ត៌មានទូរទស្សន៍ ហើយបេក្ខជនទាំងពីរភេទត្រូវមានបទពិសោធន៍ការងារផ្នែកប្រព័ន្ធផ្សព្វផ្សាយ យ៉ាងតិច៣ឆ្នាំ។

កម្មវិធី Imaging Our Mekong (www.newsmekong.org) សហការណ៍ដោយ IPS Asia-Pacific និង PMFI ដែលត្រូវបានឧបត្ថម្ភដោយអង្គការមូលនិធិ Rockefeller Foundation (South-east Asia) ប្រចាំនៅទីក្រុងបាងកក ប្រទេសថៃ ។

កម្មវិធីនេះ ជំរុញអោយមានការវិភាគ បញ្ហាឆ្លងដែនដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍន៍នៃប្រទេស និងសហគមន៍ក្នុងតំបន់ទន្លេមេគង្គ ដោយពិនិត្យមើលអោយគ្រប់ជ្រុងជ្រោយទូទាំងតំបន់ នូវព័ត៌មានទាក់ទងនឹង ព្រំដែន សាសនា ជាតិ និង នយោបាយ ។

បេក្ខជនត្រូវផ្តោតលើការរុករកនូវប្រធានបទឆ្លងដែន (ប្រធានបទដែលផ្សារភ្ជាប់ ឬពាក់ព័ន្ធរវាងប្រទេសពីរក្នុងតំបន់) ។ អទិភាពនឹងត្រូវផ្តល់ទៅអោយគំរោងណាដែលមានប្រភព

ផ្សេងៗគ្នាដែលអាចផ្តល់នូវសំលេងតែមួយ និងទិសដៅឆ្ពោះទៅកាន់កត្តា និងសហគមន៍ផ្សេងៗ ដែលរួមមានក្រុមផ្សេងៗ។

បេក្ខជនដែលបានជ្រើសរើសទាំងអស់នឹងមានឱកាសដើម្បីពង្រីកប្រធានបទនៃការធ្វើសេចក្តីរាយការណ៍របស់ខ្លួនប្រកបដោយភាពច្នៃប្រឌិត ដែលប្រធានបទអាចរាប់បញ្ចូលចាប់ពីទំនាក់ទំនងអន្តរជាតិទៅនឹងសុខភាពនិងភេទ វប្បធម៌និងជាតិពន្ធ សេដ្ឋកិច្ចនិងបរិស្ថាន និងបញ្ហាដែលផ្សារភ្ជាប់នឹងសមាហរ័ណកម្មសេដ្ឋកិច្ច។

ដំណាក់កាលអាហារូបករណ៍រួមមាន:

- ការពិនិត្យ និងការជ្រើសរើសបេក្ខជន (ទំរង់បែបបទនៃពាក្យសុំនិងគំរោងជាភាសាអង់គ្លេស និងភាសាប្រទេសទន្លេមេគង្គដទៃទៀត អាចរកបានតាមរយៈការបើកគេហទំព័រ www.newsmekong.org )

- កិច្ចសម្ភាសនានា ការស្រាវជ្រាវស៊ីជំរៅ ការស៊ើបអង្កេត និងការធ្វើដំណើរទាំងក្នុងនិងក្រៅប្រទេសរបស់បេក្ខជនដើម្បីយកព័ត៌មានពាក់ព័ន្ធទៅនឹងប្រធានបទរបស់ខ្លួន។

**បេក្ខជនដែលជាប់នឹងទទួលបានថវិកាសំរាប់ចាយវាយលើចំណាយផ្សេងៗ**

- សរសេរ ឬផលិតនូវការងាររបស់ខ្លួនដែលខ្លួនបានតាមដានរយៈពេល ៤ ខែ

នៅពេលការចាប់ផ្តើម និងនៅចុងបញ្ចប់នៃជុំអាហារូបករណ៍នីមួយៗ អ្នកដែលជាប់អាហារូបករណ៍ទាំងអស់តំរូវអោយចូលរួមសិក្ខាសាលាថ្នាក់តំបន់ចំនួនពីរលើកដែលរួមមាន សិក្ខាសាលាបើក (ថ្ងៃទី១៦-១៩ វិច្ឆិការ ២០១១) និងសិក្ខាសាលាបិទ (ខែ កុម្ភៈ ២០១២)។ សំរាប់ក្រុមទូរទស្សន៍ សិក្ខាសាលាបើកនឹងរៀបចំធ្វើឡើងតាមរយៈវគ្គបណ្តុះបណ្តាលបីថ្ងៃ (២០-២៣ ខែវិច្ឆិការ ២០១១) ជាឯកសារនិងផលិតកម្មទូរទស្សន៍។

## លទ្ធផលដែលរំពឹងទុក

ក. **អ្នកអាហារូបករណ៍ខាងសារព័ត៌មាន**: អ្នកសរសេរអត្ថបទត្រូវសរសេររឿងអោយបាន ៣០០០ ពាក្យ ហើយចុះផ្សាយនៅក្នុងកាសែតនិងទស្សនាវដ្តីរបស់ខ្លួន។ ចំពោះអ្នកថតរូបវិញ ត្រូវសរសេរអត្ថបទអោយបាន ៩០០ ពាក្យ ទៅលើរូបថតដែលបានជ្រើសរើសចំនួន ១៥ រូបថត។

ខ. **អ្នកអាហារូបករណ៍ខាងទូរទស្សន៍**: អ្នកព័ត៌មានទូរទស្សន៍ត្រូវផលិតភាពយន្តឯកសារ

អោយបានយ៉ាងហោចណាស់៨នាទីដើម្បីបញ្ចាំងតាមស្ថានីយ៍របស់ខ្លួន។ ពួកគេអាចធ្វើការជាបុគ្គល ឬជាក្រុមដើម្បីផលិតភាពយន្តឯកសារ។ ភាពយន្តឯកសារត្រូវសរសេរសេចក្តីប្រែសង្ខេបនៃសំដីរបស់តួអង្គក្នុងខ្សែភាពយន្តជាភាសាអង់គ្លេស។

អ្នកជាប់អាហារូបករណ៍អាចសរសេរគំរោង និងរឿងរបស់គេជាភាសារបស់ខ្លួន។ មូលដ្ឋានគ្រឹះ ភាសាអង់គ្លេសតំរូវចាំបាច់អោយអ្នកជាប់អាហារូបករណ៍មានសំរាប់សិក្ខាសាលា ដែលនឹងត្រូវប្រារព្ធនៅពេលចាប់ផ្តើម និងបញ្ចប់នៃកម្មវិធី ប៉ុន្តែទោះជាយ៉ាងណាក៏មានផ្តល់ការនូវការបកប្រែផងដែរ។

## បែបបទនានាដែលត្រូវដាក់

បេក្ខជនត្រូវបំពេញ ដូចតទៅ:

- ពាក្យសុំចូលរួមកម្មវិធីអាហារូបករណ៍ Imaging Our Mekong ២០១១-១២
- គំរោងដែលត្រូវទៅយកព័ត៌មាន
- ភ្ជាប់ជាមួយនូវអត្ថបទ ៣ ដែលបានចេញផ្សាយរួចដោយមានដាក់ឈ្មោះរបស់ខ្លួន (សំរាប់អ្នកសារព័ត៌មាន)។ ចំពោះអ្នកថតរូប ត្រូវភ្ជាប់នូវរូបថតចំនួន ៨ ដែលបានចេញផ្សាយរួច។
- ចំពោះអ្នកទូរទស្សន៍ ត្រូវភ្ជាប់យ៉ាងហោចណាស់ ២ TV segments ដែលបានបញ្ចាំងក្រោយពីត្រូវបានសរសេរ ដឹកនាំ ឬ កែររួចមក ដោយថតចំលងហើយផ្ញើរតាមរយ:អ៊ីម៉ែលភ្ជាប់ទៅយូធូប (You Tube) ឬ Vimeo

## ថ្ងៃផុតកំនត់នៃការទទួលពាក្យ គឺ ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១១

សូមផ្ញើពាក្យទៅអាសយដ្ឋានដូចខាងក្រោម:

The Regional Director
Imaging Our Mekong' c/o IPS Asia-Pacific
Room 3/6 K Building, 22 Sukhumvit Soi 35,
Wattana 10120 Bangkok, Thailand

Tel: (66-2) 261 8330 Fax: (66-2) 261 8331
Email: **imagingourmekong@mac.com**

សូមបើកគេហដ្ឋាន www.newsmekong.org ដើម្បីទទួលបានទំរង់បែបបទអាហារូបករណ៍។

IPS Asia-Pacific (www.ipsnewsasia.net) គឺជាអង្គការគ្មានគិតពីប្រាក់ចំណេញ ជាផ្នែករបស់ IPS international network ដែលផលិតព័ត៌មានទាក់ទងនឹង The South និងបណ្តុះបណ្តាលនិងអភិវឌ្ឍន៍ប្រព័ន្ធផ្សព្វផ្សាយ។

PMFI (www.probefound.com) គឺជាអង្គការ គ្មានភាគហ៊ុន គ្មានប្រាក់ចំណេញដែលខិតខំប្រឹងប្រែងដើម្បីការរីកចំរើនគុណភាពនៃប្រព័ន្ធផ្សព្វផ្សាយជាពិសេសទូរទស្សន៍តាមរយៈការបណ្តុះបណ្តាលអ្នកធ្វើការខាងប្រព័ន្ធផ្សព្វផ្សាយដែលមានវិជ្ជាជីវៈនិងអ្នកដែលចង់ចេះ។

កម្មវិធី The Imaging Our Mekong ត្រូវបានឧបត្ថម្ភដោយ THE ROCKEFELLER FOUNDATION ។